**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## <u>កិច្ចព្រមព្រៀង</u>

ថ្ងៃចន្ទ ៥កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ពស ២៥៦៤ ត្រូវនឹងថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ២០២០ វេលាម៉ោង ១០:០០នាទីព្រឹកនៅក្នុងរោងចក្រ សាន់ប្រ៊េសស្គ័ត(ខេមបូឌា)ខូអិលធីឌី ឯ.ក អាស័យដ្ឋានអាគារទី០៧ នៃសួនឧស្សាហកម្មសំរោងធំ ផ្លូវជាតិលេខ១ ភូមិព្រៃកគ្រែង ឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្ដាល ប្រទេសកម្ពុជា។ បានបើកកិច្ចប្រជុំពិភាក្សាគ្នាមួយរវាងរោងចក្រ និង ប្រធានក្រុមព្រមទាំងតំណាងកម្មករនិយោជិតទាំងអស់។

### ១. <u>សមាសភាពអ្នកចូលរួម</u>

#### ក. <u>ភាគីតំណាងអោយក្រុមហ៊ុន</u>

-លោកស្រី GUO ZHEN ZHEN (ប្រធានផ្នែករដ្ឋបាល)

-លោកស្រី សឿន ចិន្តា (ជំនួយការផ្នែករដ្ឋបាល)

#### ខ. <u>ភាគីតំណាងកម្មករនិយោជិត</u>

១-លោក: ផាត ភារម្យ ២-អ្នកស្រី: ចយ ស្រីនាង ៣-លោក: វ៉ាន់ វណ្ណៈ ៤-លោក: យី មីជា

៥-អ្នកស្រី: មៅ ស្រីពៅ ៦-អ្នកស្រី: ឡុន មករា ៧-អ្នកស្រី: នាង ស្រីមុំ

### ២.<u>ខ្លឹមសារអង្គប្រជុំ</u>

សមាជិកអង្គប្រជុំទាំងមូលបានលើកឡើងអំពីបញ្ហាការព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ៥០០នាក់ ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន ៥៣១នាក់ (ស្រី៤៨៩នាក់) នៅក្នុងរោងចក្រក្នុងរយៈពេល២ខែ ដោយចាប់ពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២០ ដល់ថ្ងៃទី២៥ ខែ ធ្នូ ឆ្នាំ២០២០ ដោយជួបបញ្ហាដោយសារវិបត្តិកូវីតដែលបណ្ដាលអោយពុំមានការបញ្ជាទិញ។

ឆ្លងតាមការពិភាក្សា និងយោងតាមការសម្របសម្រួលស្ម័គ្រចិត្តដោះស្រាយដោយផ្ដល់ឲ្យភាគីនីមួយៗមានលទ្ធភាពទទួលយកបាន និងបង្កលក្ខណៈដោះស្រាយតាមស្ថានភាពជាក់ស្ដែងដោយទាំងតំណាងរោងចក្រក៏ដូចជាផ្នែកតំណាងកម្មករនិយោជិតនិង ប្រធានក្រុមទាំងអស់បានព្រមព្រៀងគ្នាតាមវិធីដោះស្រាយដូចខាងក្រោម៖

១.រោងចក្រឯកភាពផ្ដល់ជូនកម្មករនិយោជិតដូចមានក្នុង សេចក្ដីជូនដំណឹងលេខ០៤៥/២០នៃក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ។ ដែលបានពន្យល់ដូចខាងក្រោម៖

- ចំនួន ១០ដុល្លារអាមេរិកសម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១០ថ្ងៃ
- ចំនួន ២០ដុល្លារអាមេរិកសម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ
- ចំនួន៣០ដុល្លារអាមេរិកសម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ២១ថ្ងៃ ដល់មួយខែ។

២.យល់ព្រមបើកប្រាក់បៀវត្សចុងក្រោយរួមនិង ប្រាក់ឧបត្ថម្ភសម្រាប់ការព្យួរកិច្ចសន្យាការងារខែទីមួយ នៅថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០២០ ។

៣.សម្រាប់ប្រាក់ឧបត្ថម្ភខែចុងក្រោយនៃការព្យួរការងារនិងបើកនៅពេលត្រលប់ចូលធ្វើការធម្មតាវិញ។

**<u>លទ្ធផលអង្គប្រជុំ</u>**

ជាលទ្ធផល នៃការពិភាក្សាភាគី ទាំងពីរបានឯកភាពគ្នាដូចខាងក្រោម:

១.រោងចក្រចាប់ផ្តើមព្យួរកិច្ចសន្យាការងារកម្មករនិយោជិតដោយគិតចាប់ផ្តើមពីថ្ងៃទី២៦ ខែតុលា ឆ្នាំ ២០២០ រហូតដល់ថ្ងៃទី២៥ ខែ ធ្នូ ឆ្នាំ២០២០។

២.រោងចក្រឯកភាពផ្តល់ជូនកម្មករនិយោជិតដូចមានក្នុង សេចក្តីជូនដំណឹងលេខ០៤៥/២០នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

៣.យល់ព្រមបើកប្រាក់បៀវត្សចុងក្រោយរួមនិង ប្រាក់ឧបត្ថម្ភសម្រាប់ការព្យួរកិច្ចសន្យាការងារខែទីមួយ នៅថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០២០ ។

៤.សម្រាប់ប្រាក់ឧបត្ថម្ភខែចុងក្រោយនៃការព្យួរការងារនិងបើកនៅពេលត្រលប់ចូលធ្វើការធម្មតាវិញ។

<u>បញ្ជាក់:</u> ករណីដែលរោងចក្រមានការងារធ្វើក្នុងកំឡុងពេលព្យួរ រោងចក្រនិងអនុញ្ញាតិអោយកម្មករ និយោជិតចូលធ្វើការមុនពេលកំណត់។

អង្គប្រជុំបានចប់សព្វគ្រប់នៅម៉ោង ១១:០០ នាទីនាថ្ងៃដដែល។ ក្រោមបរិយាកាសរីករាយ និងមនោសញ្ចេតនាជាភាតរភាព ដោយបានចុះហត្ថលេខាក្នុងកំណត់ហេតុទុកជាភស្តុតាំងផងដែរ។

**ក.ភាគីតំណាងអោយក្រុមហ៊ុន**

-លោកស្រី GUO ZHEN ZHEN

-លោកស្រី សឿន ចិន្តា

**ខ.<u>ភាគីតំណាងកម្មករ និយោជិត</u>**

១-លោក: ផាត ភារម្យ ២-អ្នកស្រី: ចយ ស្រីនាង ៣-លោក: វ៉ាន់ វណ្ណៈ ៤-លោក: យី មីដា

៥-អ្នកស្រី: ម៉ៅ ស្រីពៅ ៦-អ្នកស្រី: ឡុន មករា ៧-អ្នកស្រី: នាង ស្រីមុំ

**គ.<u>ភាគីប្រធានក្រុម</u>**

**១**-អ្នកស្រី ប៊ិច សុជាតិ ២-អ្នកស្រី លី បូរ៉ា ៣-អ្នកស្រី ឡេង សំអាត ៤-កញ្ញា យ៉ុម ស្រីនិច

៥- អ្នកស្រី ផាត ស្រីហ៊ិន ៦-អ្នកស្រី ហោង ស្រស់ ៧- កញ្ញា សុន ទីវី ៨- លោក សុន ចន្ធី

៩- អ្នកស្រី អោម វណ្ណា: ១០- កញ្ញា ភន លីណា ១១- កញ្ញា ធឿន មួយឡាយ

ថ្ងៃច័ន្ទ ៥កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ពស ២៥៦៤

សាន់ហ្គ្រេស ស្ព័ត ថ្ងៃទី២២ខែកញ្ញា ឆ្នាំ២០២០

ហត្ថលេខា និងត្រា

**ប្រធានរោងចក្រ**

SUN GRACE SPORTS (CAMBODIA) CO., LTD.
KINGDOM OF CAMBODIA